# ក្រសួងមហាផ្ទៃបញ្ជាទៅអភិបាលខេត្តកណ្ដាល ដោះស្រាយបញ្ហាដីធ្លីជូនពលរដ្ឋដែលប៉ះពាល់ ដោយព្រលានយន្តហោះថ្មី។




អ្នកភូមិប្រហែល១០០នាក់ តំណាងឱ្យពលរដ្ឋ៤៧៣គ្រួសារ មកពីឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង និងសង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល បានជួបជុំគ្នានៅក្នុងសហគមន៍ ធ្វើសន្និសីទកាសែតមួយ ដើម្បីអំពាវនាវដល់ប្រមុខរដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធ អនុញ្ញាតឱ្យពួកគេបានអភិវឌ្ឍន៍នៅនឹងកន្លែង និងចេញបណ្ណកម្មសិទ្ធិ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣។ (ហ៊ាន រង្សី)

ក្រសួងមហាផ្ទៃ បានបញ្ជាទៅអភិបាលខេត្តកណ្ដាល ឱ្យដោះស្រាយបញ្ហាដីធ្លីជូនប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយគម្រោងអភិវឌ្ឍន៍ព្រលានយន្តហោះអន្តរជាតិភ្នំពេញថ្មី នៅខេត្តកណ្ដាល។

កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២ ពលរដ្ឋ ៩នាក់ តំណាងឱ្យពលរដ្ឋ ៦៩គ្រួសារ នៅឃុំព្រែកស្លែង និងឃុំបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល បាននាំគ្នាដាក់ញត្តិទៅក្រសួងមហាផ្ទៃ ដើម្បីសុំអន្តរាគមន៍ជួយដោះស្រាយទំនាស់ដីធ្លីជាមួយក្រុមហ៊ុន OCIC និង CAIC ដែលទទួលបានសិទ្ធិសាងសង់ព្រលានយន្តហោះភ្នំពេញថ្មី នៅខេត្តកណ្ដាល។

បើតាមញត្តិពលរដ្ឋ គឺពួកគេ ៦៩គ្រួសារនោះបានប៉ះពាល់ក្បាលដី **១២៩**ក្បាលដី ឬស្មើទំហំដីសរុបជាង **៨៨ (៨៨០ ៥១២)** ម៉ឺនម៉ែត្រការ៉េ។ ក្នុងញត្តិនេះ ពលរដ្ឋបានប្រាប់ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក **ស ខេង** ថាក្រុមហ៊ុនអភិវឌ្ឍន៍ព្រលានយន្តហោះ បានប្រើប្រាស់គ្រឿងចក្រឈូសឆាយរំលោភយកដីធ្លីរបស់ពួកគេដែលមានបណ្ណកម្មសិទ្ធិស្របច្បាប់។

ញត្តិដដែលបន្តថា ការដោះស្រាយកន្លងមក គឺអាជ្ញាធរផ្ដល់សំណង **១ម៉ែត្រការ៉េត្រឹម៨ដុល្លារ** ប៉ុណ្ណោះ ដែលការដោះស្រាយនេះ ពលរដ្ឋមិនអាចទទួលយកបានដោយសារតិចតួចពេក ខណៈបច្ចុប្បន្ន ដីនៅជាប់តំបន់នោះមានតម្លៃចន្លោះពី ៥០ដុល្លារទៅ ៨០ដុល្លារ ក្នុង១ម៉ែត្រការ៉េ។ ក្រុមពលរដ្ឋបានស្នើដល់ក្រសួងមហាផ្ទៃជួយអន្តរាគមន៍ដោះស្រាយឱ្យបានតម្លៃ ៦០ដុល្លារក្នុង១ម៉ែត្រការ៉េ។

យោងតាមលិខិតចុះទី៣០ ខែមករា ឆ្នាំ២០២៣ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក **ស ខេង** បានបញ្ជាទៅអភិបាលខេត្តកណ្ដាល លោក **គង់ សោភ័ណ្ឌ** ចាត់ចែងមន្ត្រីចុះ

ពិនិត្យសិក្សា ស្រាវជ្រាវ និងដោះស្រាយជូនពលរដ្ឋ ដោយផ្អែកលើគោលការណ៍ច្បាប់ ហើយឆ្លើយតបទៅប្រជាពលរដ្ឋវិញផងដែរ។

តំណាងពលរដ្ឋនៅឃុំបឹងខ្យាង អ្នកស្រី **យឹម ម៉ាលី** ប្រាប់វីអូឌីថា រហូតមកដល់ថ្ងៃទី១០ ខែកុម្ភៈនេះ ពុំទាន់មានអាជ្ញាធរណាចុះមកដោះស្រាយសំណងផលប៉ះពាល់ដីស្រែជូនពលរដ្ឋជាថ្មីទៀតនោះទេ ក្រៅពីបង្ខំឱ្យទទួលយកសំណងត្រឹម៨ដុល្លារក្នុង១ម៉ែត្រការ៉េ និងឱ្យពលរដ្ឋដាក់តម្លៃប៉ះពាល់ផ្ទះសម្បែង រួមទាំងផលដំណាំផ្សេងៗ។

តំណាងពលរដ្ឋរូបនេះបានឱ្យដឹងថា គ្រួសារអ្នកស្រីប៉ះពាល់ដីស្រែ **៣០អា** និងដីលំនៅឋាន **២០ម៉ែត្រ គុណ ៤០ម៉ែត្រ**។ អ្នកស្រីថា បើអាជ្ញាធរនៅតែដោះស្រាយត្រឹម៨ដុល្លារក្នុង១ម៉ែត្រការ៉េនោះ គឺអ្នកស្រីមិនអាចទទួលយកបានឡើយ ដោយសារសំណងនេះតិចតួចពេក មិនអាចយកទៅទិញដីនៅតំបន់នោះបាន។

អ្នកស្រីបន្ថែមថា៖ **«អត់មានឃើញគេចុះមកដោះស្រាយអីទៀតផង។ ក្រសួងចេញលិខិត ចេះតែចេញ អ៊ីចឹងដូចពួកបងយកទៅដាក់ខាង ម៉ែន សំអន [ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច] អ៊ីចឹងគេចេញមកអ៊ីចឹងដែរ តែគេគ្មានការអន្តរាគមន៍ដោះស្រាយឱ្យផង។ ឥលូវក្រុមហ៊ុនគេធ្វើសកម្មភាពឈូសឆាយទៅមុខ ចង់រួចហើយ។ គេឈូសយកដីប្រជាពលរដ្ឋខ្ទេចខ្ទីអស់ហើយ»**។

ពលរដ្ឋនៅឃុំបឹងខ្យាង លោក **ទូន វណ្ណៈ** និយាយថា គ្រួសារលោកប៉ះពាល់ដីស្រែ និងដីលំនៅឋាន សរុប២ហិកតា។ លោកថា ចាប់តាំងពីក្រុមហ៊ុនឈូសឆាយយកដីស្រែរបស់លោកអស់មក គឺគ្រួសារលោកជួបបញ្ហាជីវភាពជាខ្លាំង ដោយគ្មានដីសម្រាប់បង្កបង្កើនផល និងការបាត់បង់ការងារធ្វើ ជាដើម។

លោកបន្ថែមថា៖ «កាលពីដើមឡើយ ខ្ញុំរស់ដោយសារការធ្វើស្រែយកស្រូវទៅលក់ ហើយដល់ឥលូវ វាអត់មានស្រែធ្វើ ហើយអត់ការងារធ្វើ តើខ្ញុំរស់ពឹងអី? ប្រសិនបើគោលការណ៍ដោះស្រាយនៅតែ ៨ដុល្លារក្នុង១ម៉ែត្រការ៉េ ពួកខ្ញុំមិនដឹងទៅទីពឹងអី យកក៏នៅតែក្រ មិនយកក៏នៅតែក្រ។ អ៊ីចឹងពួកខ្ញុំអត់ទទួល ព្រោះថា ដីខ្ញុំជាដីមានប្លង់ស្របច្បាប់ មិនមែនខ្ញុំចេះតែចូលធ្វើដោយខ្លួនឯងទេ ហើយខ្ញុំក៏មិនប្រឆាំងជាមួយការអភិវឌ្ឍដែរ ប្រសិនជាការអភិវឌ្ឍនោះស្របទៅតាមច្បាប់»។

អភិបាលខេត្តកណ្ដាល លោក **គង់ សោភ័ណ្ឌ** ប្រាប់ វីអូឌីថា កំពុងជាប់រវល់ប្រជុំ មិនអាចនិយាយបាន។ យ៉ាងណា លោកធ្លាប់ប្រាប់វីអូឌីថា អាជ្ញាធរមិនអាចដោះស្រាយលើសពី៨ដុល្លារនេះបានទេ ព្រោះថា សំណងនេះកំណត់ជាគោលការណ៍ដោយរដ្ឋាភិបាល។

មន្ត្រីសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្ស នៅមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក **វណ្ណ សុផាត** មានប្រសាសន៍ថា ករណីក្រសួងមហាផ្ទៃចេញលិខិតឱ្យអាជ្ញាធរខេត្តចុះពិនិត្យ និងដោះស្រាយជូនពលរដ្ឋនេះ គឺលោកមិនមានជំនឿថាដោះស្រាយបាន និងមានប្រសិទ្ធភាពនោះទេ។

អ្នកការពារសិទ្ធិមនុស្សរូបនេះបានលើកឡើងថា នេះមិនមែនជាលើកទី១នោះទេ ដែលក្រសួងមួយនេះបានចេញលិខិតឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិ ដោះស្រាយបញ្ហាដីធ្លីជូនពលរដ្ឋ ក្រោយពីពលរដ្ឋរកកិច្ចអន្តរាគមន៍ពីក្រសួងទាំងនោះ ប៉ុន្តែអាជ្ញាធរថ្នាក់ក្រោមជាតិ មិនដែលដោះស្រាយជូនពលរដ្ឋបានឡើយ។

លោក **វណ្ណ សុផាត** បានលើកឡើងថា តាមច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់ភូមិបាល និងច្បាប់អស្សាមិករណ៍ គឺរដ្ឋអាចដកហូតដីពលរដ្ឋមានបណ្ណកម្មសិទ្ធិស្របច្បាប់ទៅ

អភិវឌ្ឍបាន លុះត្រាតែមានការផ្ដល់សំណងសមរម្យ និងមានការយល់ស្របពីម្ចាស់អចលនវត្ថុផងដែរ។

លោកបន្ថែមថា៖ «បើសិនមានដីកាសម្រេចពីក្រសួងស្ថាប័នដែលពាក់ព័ន្ធ ជាពិសេសអន្តរក្រសួង ឬក្រសួងដែនដី ឬមានប្រកាសពីប្រមុខរដ្ឋាភិបាលអី អាហ្នឹងបានមានអំណាចក្នុងការដោះស្រាយជូនពលរដ្ឋទាំងអស់ហ្នឹងបាន។ បើគ្រាន់តែក្រសួងមហាផ្ទៃ ឱ្យថ្នាក់ខេត្តចុះពិនិត្យស៊ើបអង្កេត ហើយបានរបាយការណ៍ទៅក្រសួងវិញ អាហ្នឹងការដោះស្រាយនោះគ្មានប្រសិទ្ធភាពអីទេ»។

កាលពីថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០ រដ្ឋាភិបាលបានចេញអនុក្រឹត្យមួយដោយផ្ដល់ដីរដ្ឋទំហំប្រមាណ២ ៦០០ហិកតា ដែលលាតសន្ធឹងលើស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល និងស្រុកបាទី ខេត្តតាកែវ ទៅឱ្យក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានកម្ពុជា (CAIC) វិនិយោគរួមគ្នាជាមួយសាជីវកម្មក្រៅប្រទេស និងលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីអភិវឌ្ឍព្រលានយន្តហោះអន្តរជាតិភ្នំពេញថ្មីមួយនេះ។

ក្នុងលិខិតចំហមួយរបស់ប្រជាពលរដ្ឋ ដែលផ្សាយកាលពីខែកក្កដា ឆ្នាំ២០២១ បានអះអាងថា គម្រោងអភិវឌ្ឍន៍ព្រលានយន្តហោះអន្តរជាតិភ្នំពេញថ្មីនេះ បានធ្វើឱ្យប៉ះពាល់ប្រជាពលរដ្ឋ ៣៣០គ្រួសារ និងដីទំហំជាង១លានម៉ែត្រការ៉េ ដែលភាគច្រើនជាដីមានបណ្ណកម្មសិទ្ធិស្របច្បាប់ ស្ថិតក្នុងឃុំចំនួន៤ រួមមាន ឃុំបឹងខ្យាង ឃុំអំពៅព្រៃ ឃុំព្រែកស្លែង ក្នុងស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល និងឃុំពត់សរ នៅស្រុកបាទី ខេត្តតាកែវ៕